និពន្ធដោយ អ៊ឹម រចនា

# ឆ្លងឆ្នាំ

សមាគមសេរីភាព
LIBERTY ASSOCIATION

និពន្ធដោយ អ៊ឹម រចនា

# ភ្លូខក្លាំ

មករា 2012

សមាគមសេរីភាព
LIBERTY ASSOCIATION

បោះពុម្ពផ្សាយដោយ សមាគមសេរីភាព
ផ្ទះលេខ 53 CE0 ផ្លូវ242
សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ
ប្រទេសកម្ពុជា

Liberty Association
#53 CE0, St 242
Chaktomuk, Daun Penh, Phnom Penh
Cambodia

khmerphnompenh.wordpress.com

ទំនាក់ទំនង ៖ **cambocanada@gmail.com**

គ្រប់មាតិកានៃរឿងនេះជាកម្មសិទ្ធិបញ្ញា
របស់ កញ្ញា **អ៊ឹម រចនា**។

នេះគឺជាសៀវភៅរឿងប្រលោមលោកបែបច្នៃប្រឌិត។ ឈ្មោះតួអង្គ ទីកន្លែង និង
ហេតុការណ៍តួអង្គនៅក្នុងសៀវភៅនេះ សុទ្ធតែជាការស្រមើស្រមៃ។

រាល់ព្រឹត្តិការណ៍ ដែលស្រដៀង រឺដូចគ្នាទៅនឹងភាពជាក់ស្តែង បុគ្គល
(នៅរស់ រឺស្លាប់) និងទីកន្លែង រឺស្ថាប័ន គឺជាការចៃដន្យតែប៉ុណ្ណោះ។

*[ម៉ោង13.30នាទី]*

មួយឆ្នាំៗកន្លងទៅលឿនមែនទែន! ថ្ងៃនេះ ជាថ្ងៃទី៣១ ខែធ្នូ ជាថ្ងៃដែលគ្រប់គ្នារាប់ថយក្រោយអបអរសាទរឆ្នាំថ្មីដែលរត់ចូលមកបន្ថែមអាយុឲ្យចាស់មួយឆ្នាំទៀត។ អ្នកខ្លះធ្វើដំណើរទៅរាប់ថយក្រោយឯខេត្តផ្សេងៗ ព្រោះគិតថាសប្បាយ តែខ្ញុំថា ដេកនៅផ្ទះសប្បាយជាង! យប់ឆ្លងឆ្នាំហាក់ដូចជាគ្មានអីអស្ចារ្យនោះទេសម្រាប់ខ្ញុំ! វាគ្រាន់តែជាយប់ដ៏ឯកាមួយទៀត ដែលខ្ញុំត្រូវចំណាយពេលដកដង្ហើមជាងដប់ម៉ោង រង់ចាំឲ្យពេលព្រឹកមកដល់តែប៉ុណ្ណោះ។

ថ្ងៃ៣១ធ្នូដដែល ជាថ្ងៃដែលគ្រប់គ្នាឈប់សម្រាក តែវាជាថ្ងៃដែលខ្ញុំនៅតែធ្វើការ... បើគ្រាន់តែសម្រាកនៅផ្ទះ ដកដង្ហើមចោលដដែល ទៅធ្វើការមិនល្អជាងឬ? សង្សារក៏គ្មាន មិត្តភក្តិក៏ការចោលអស់ទៀត បើឲ្យខ្ញុំនៅសំកុកឯផ្ទះតែឯងទៀត ខ្ញុំប្រាកដជាស្លាប់មុននឹងបានការប្រពន្ធមិនខានទេ។

សំឡេងទូរស័ព្ទរោទិ៍បង្អាក់ការគិតរបស់ខ្ញុំដែលកំពុងអណ្ដែតទៅលើលំហអាកាសផុតឆ្ងាយពីពំនូកការងាររបស់ខ្ញុំដែលមាននៅចំពោះមុខៗ ខ្ញុំទទួលទូរស័ព្ទទាំងអារម្មណ៍ហាត់នឿយ... នរណាខលមកអ៊ីចេះ?

- អាឡូ ជម្រាបសួរ!

សំឡេងបុរសអាយុប្រមាណ២០ឆ្នាំបន្លឺតបមកខ្ញុំ ៖

- បាទជម្រាបសួរបង! ខ្ញុំខលពីសណ្ឋាគារកំពង់សោម ចង់បញ្ជាក់បង រឿងបន្ទប់សម្រាប់យប់នេះ...

- អំ! អរគុណហើយដែលខលមកសួរ.. បងនៅទៅទេតើ! ប្រហែលម៉ោង៦ល្ងាចបងទៅដល់ហើយ...

- បាទ! អ៊ីចឹងចាំខ្ញុំទុកបន្ទប់ជូន... អរគុណច្រើនបង ជម្រាបលា!»

ត្រូវហើយ! ខ្ញុំប៊ិះនឹងភ្លេចទៅថាខ្ញុំត្រូវទៅជួបភ្ញៀវនៅកំពង់សោមល្ងាចនេះ... ដាច់ឆ្នាំ ការងារដែលនៅសល់ទាំងប៉ុន្មានក៏ត្រូវជម្រះឲ្យរួចស្រេចកុំឲ្យសេសសល់ដល់ឆ្នាំថ្មីនាំ

ហ្មងសៅ។ និយាយទៅ ការងារដែលត្រូវធ្វើនៅកំពង់សោមក៏មានមិនច្រើនប៉ុន្មានដែរ។ ខ្ញុំគ្រាន់តែត្រូវជួបភ្ញៀវប៉ុន្មាននាក់ពិនិត្យបញ្ជី ហើយរួចពីនោះក៏ទំនេរល្មមនឹងអង្គុយផឹកឆ្លងឆ្នាំតែម្នាក់ឯងនៅឆ្នេរ ហើយថែមទាំងសល់ពេលទំនេរពីរថ្ងៃទៀតទុកសម្រាប់ទៅដេកលេងលើកោះឬស្សី មើលផ្កាយ និងស្តាប់សំឡេងទឹករលកនាពេលយប់... គ្រាន់តែស្រមៃក៏សប្បាយចិត្តទៅហើយ។

មនុស្សនៅម្នាក់ឯងគួរតែប្រើពេលវេលាឯកានេះឲ្យមានប្រយោជន៍ ហើយខ្ញុំថា គ្មានអ្វីល្អជាងចំណាយពេលវេលាអស់នេះលើការងារនោះទេ... ហើយបើមានពេលទំនេរក៏ទៅដើរលេងបែបម្នាក់ឯង... ងាយៗ!

*[ម៉ោង18.47នាទី]*

កំពង់សោមថ្ងៃនេះអ៊ូអរជាងសព្វដង។ តាមផ្ទះសំណាក់និងសណ្ឋាគារមានរថយន្តចតព្រាត ចំណែកមនុស្សម្នាក៏ច្រើន ពិសេសនៅតាមឆ្នេរ ឃើញថាមានមនុស្សមកលេងច្រើនស្ទើរតែរកកន្លែងអង្គុយមិនបាន។ ជិះក្រវែលក្រុងបានបន្តិច ខ្ញុំក៏បត់ឡានតម្រង់សណ្ឋាគារដែលខលមកខ្ញុំថ្ងៃមិញនេះ... បើកុំតែជាម៉ូយប្រចាំនៅទីនោះ មកជួបភ្ញៀវលើកនេះខ្ញុំអាចនឹងគ្មានកន្លែងគេង ហើយអាចនឹងត្រូវគេងក្នុងឡានជំនួសក៏ថាបាន។ សណ្ឋាគារដែលខ្ញុំឧស្សាហ៍មកគេងនេះតូច តែស្អាត ហើយនៅជិតក្រុង... តែហេតុផលពិតប្រាកដដែលធ្វើឲ្យខ្ញុំមកគេងនៅទីនេះនោះគឺដោយសារតែនៅក្បែរនេះមានម៉ាតតូចមួយដែលមានម្ចាស់ស្អាត។ មកម្ដងណាក៏ខ្ញុំមិនដែលភ្លេចឈៀងចូលមើលមុខម្ចាស់ហាងដែរ។ ខ្ញុំស្គាល់នាងពីរឆ្នាំមកហើយ គឺចាប់តាំងពីខ្ញុំចាប់ចុះមកធ្វើការនៅខេត្តកំពង់សោមនេះដំបូងម្ល៉េះ។

ចាំបានថាកាលនោះ ខ្ញុំចេញពីជួបភ្ញៀវទាំងស្រវឹង ហើយក៏ចូលម៉ាតរបស់នាងដែលនៅក្បែរកន្លែងគេងដើម្បីរកអីជូរៗផឹកក្រែងបានធូរ ព្រោះថាត្រូវបើកឡានឡើងទៅភ្នំពេញវិញនាពេលព្រឹក។ ខណៈពេលដែលខ្ញុំកំពុងឈរមុខទូក្លាសេដែលមានដាក់តាំងភេសជ្ជៈជាច្រើនមុខ ច្រើនរហូតមិនដឹងថាគួរតែផឹកអីទើបអាចជួយបាននោះ សំឡេងនរណាម្នាក់បន្លឺសួរពីក្រោយខ្នងខ្ញុំថា ៖

- ...ចង់ដេកឬចង់ដើរ?

សំណួរប្លែកៗនេះធ្វើឲ្យខ្ញុំអត់មិនងាកក្រោយរកមើលម្ចាស់សំណួរមិនបាន។ នារីក្នុងវ័យ២២ឆ្នាំម្នាក់កំពុងឈរឱបដៃសម្លឹងមើលមកខ្ញុំយ៉ាងចម្លែក។ ពេលដែលឃើញខ្ញុំងាកទៅទាំងឆ្ងល់ទើបនាងញញឹមយ៉ាងហួសចិត្ត ៖

- ...បើចង់ដេក យកអានោះ!

នាងនិយាយដោយចង្អុលទៅទូតាំងស្រាបៀរនិងគ្រឿងស្រវឹងផ្សេងទៀតជាច្រើន រួចបន្ត ៖

- តែបើចង់ដើរ ត្រូវយកអានេះ...

និយាយចប់នាងឱនយកភេសជ្ជៈបាកាសពីកេសក្បែរជើងរបស់នាងមកដាក់តម្រៀបបន្ថែមនៅក្នុងទូកញ្ចក់ត្លាសេ។ ពេលរៀបរួច នាងងើបមកសម្លឹងខ្ញុំម្តងទៀតក្នុងក្រសែភ្នែកចង់បានចម្លើយ។ ខ្ញុំញញឹមបន្តិចទើបឆ្លើយ ៖

- ខ្ញុំថា ដើរល្អជាងដេក!

នាងញញឹមតបរួចបើកទូយកភេសជ្ជៈបាកាសមួយកំប៉ុងហុចមកឲ្យខ្ញុំ មុននឹងដើរនាំមុខខ្ញុំតម្រង់ទៅកន្លែងគិតលុយដែលនៅក្បែរទ្វារចេញរបស់ម៉ាត។ មិនដឹងថាមានមនុស្សប៉ុន្មាននាក់ដែលជឿលើស្នេហាដែលឃើញភ្លាមស្រឡាញ់ភ្លែត? អ្នកប្រហែលជាមិនជឿ តែខ្ញុំចង់ប្រាប់ថារឿងស្នេហាបែបនេះពិតជាមាន... ព្រោះថា វាកំពុងតែកើតឡើងចំពោះខ្ញុំផ្ទាល់។ ចាប់ពីពេលដែលនាងសម្លឹងខ្ញុំដំបូង កែវភ្នែកដ៏សែនជ្រៅមួយគូនោះធ្វើឲ្យខ្ញុំដឹងថា នាងគឺជាមនុស្សដែលខ្ញុំរង់ចាំជាយូរ... ភ្លាមនោះ ខ្ញុំដឹងខ្លួនរួចជាស្រេចថា ខ្ញុំមានជម្រើសពីរគឺបោះបង់និងចាប់យក... ហើយជម្រើសរបស់ខ្ញុំគឺ...

*[ម៉ោង23.15នាទី]*

- បងសិដ្ឋ!

ខ្ញុំងាកទៅញញឹមដាក់ប្រុសកម្លោះដែលកំពុងឈរគិតលុយឲ្យជនបរទេសនៅក្នុងម៉ាតក្បែរសណ្ឋាគារដែលខ្ញុំគេង៖

- ម៉េចហើយយុទ្ធ? ដាច់ទេ?

យុទ្ធញញឹមស្រស់រួចតបមកខ្ញុំយ៉ាងរួសរាយ៖

- ដាច់ខ្លាំងណាស់បង... ឥវ៉ាន់សឹងតែដាច់អស់ពីស្តុកហើយ!

និយាយចប់មិនទាន់ យុទ្ធសើចយ៉ាងសប្បាយចិត្ត។

- ចុះយ៉ាអត់មកលក់ទេឬថ្ងៃនេះ?

ខ្ញុំសួររកកិត្យា នារីដែលខ្ញុំចង់ជួបយ៉ាងមិនក្រែងចិត្តប្អូនប្រុសគេ ដែលកំពុងតែឈរចំពោះមុខខ្ញុំ...

- បងយ៉ាទៅឆ្មេរមុននេះបន្តិច... បងមិនបានប្រាប់គាត់ថាបងមកទេឬ?

ខ្ញុំគ្រវីក្បាលតបៈ

- អត់ទេ! គិតថាមកធ្វើឲ្យភ្ញាក់ផ្អើល មិនដឹងថាគេទៅដើរលេងចោលបែបនេះឯណា?»

*[ម៉ោង23.55នាទី]*

នៅលើឆ្នេរ មនុស្សច្រើនកកកុញ។ ខ្ញុំដើរតាមឆ្នេរ មើលពំនូកខ្សាច់ដែលគេពូនប្លែកៗលម្អដោយទៀនអុជភ្លឺរន្ទាល ជាមួយនឹងពាក្យអបអរឆ្នាំថ្មី។ ក្មេងៗចាប់អុជកាំជ្រួច ចំណែកចាស់ៗនៅអង្គុយជុំគ្នាទទួលទានអាហារសមុទ្រមិនទាន់ងើបនៅឡើយ។ កន្លែងខ្លះមានក្មេងជំទង់នាំគ្នារាំញាក់ជុំមិត្តភក្តិស្រវាលៗគ្នាយ៉ាងសប្បាយ។ នរណាទៅចង់ឆ្លងឆ្នាំតែឯងនោះ? ខ្ញុំលើកទូរស័ព្ទឡើងខលទៅលេខកិត្យា...

- ស្ហូស្តីឆ្នាំថ្មី អ្នកប្រមឹក!

ខ្ញុំញញឹមរាល់ពេលដែលនាងហៅខ្ញុំបែបនេះ... នាងជួបខ្ញុំដំបូងនៅពេលដែលខ្ញុំស្រវឹង ហើយចាប់តាំងពីពេលនោះមក ខ្ញុំក៏ត្រូវជាប់ឈ្មោះបែបនេះរហូត។ ខ្ញុំជាមនុស្សប្រមឹកឬអត់នោះ មានតែនាងទេដែលដឹង!

- សួស្ដីឆ្នាំថ្មី... ជូនពរឲ្យម្ចាស់ម៉ាតជួបតែក្ដីសុខ!

- សុំពរអីផ្សេងបានអត់?

មានប៉ុន្មាននាក់ដែលនឹងមកតថ្លៃរឿងពរឆ្នាំថ្មីជាមួយខ្ញុំបែបនេះ? ប្រហែលជាមានតែកិត្យាតែម្នាក់គត់...

- តថ្លៃពរឆ្នាំថ្មីបែបហ្នឹង សង្ស័យពរតែលែងស័ក្តិសិទ្ធទេ...

- ទេវតាមិនចិត្តអាក្រក់ដល់ម្លឹងទេហ្អី?

ខ្ញុំសើចនឹងពាក្យមិនដឹងខ្យល់របស់នាង៖

- អូខេៗ! ចង់បានពរអីក៏សុំមកចុះ...

- មិនសុំអីច្រើនទេ! សុំឲ្យប្រាថ្នាអីបានសម្រេចដូចបំណង... តែប៉ុណ្ណឹង! ...អ៎! និយាយអ៊ីចឹង បងនៅឯណាហ្នឹង? យ៉ានៅឆ្មេរ។ មនុស្សច្រើនដល់ហើយ!

- បងក៏នៅឆ្មេរដែរ...

យ៉ាស្ងាត់ទៅមួយសន្ទុះ ទើបសួរត្រឡប់៖

- បងមកកំពង់សោម? ហេតុអីមិនប្រាប់? ចុះក្រែងថាមិនចូលចិត្តឆ្លងឆ្នាំ មិនចូលចិត្តមនុស្សច្រើន មិនអ៊ីចឹងឬ?

សួរមកច្រើនបែបនេះ គួរឆ្លើយមួយណាមុនល្អណ៎?

- បងមកជួបភ្ញៀវពីល្ងាច... មិនបានប្រាប់ព្រោះចង់ឲ្យភ្ញាក់ផ្អើល ហើយការពិតទៅក៏មិនចង់មកឆ្មេរប៉ុន្មានដែរព្រោះមនុស្សវាច្រើនពេក តែ...

ខ្ញុំផ្អាកបន្តិច តែជើងក៏ដើរទៅមុខរឿយៗដោយគិតបណ្ដើរថាគួរឆ្លើយសំណួរមួយនេះបែបណា?

សំឡេងរាប់ថយក្រោយចាប់ផ្ដើមបន្លឺឡើង... ស្នូរកាំជ្រួចតូចៗក៏ចាប់ផ្ដើមលាន់ច្រើនឡើងៗ តែសំឡេងកិត្យាមិនឮស្លូម្បីបន្តិច... ខ្ញុំមិនខ្វល់ពីអ្នកដែលនៅក្បែរខាងដែលកំពុងរំភើបជ្រួលជាមួយនឹងការឆ្លងឆ្នាំ ដោយនៅតែដើរទៅមុខរហូតឃើញស្រមោលនរណាម្នាក់ដែលកំពុងដើរបញ្ច្រាសមករកខ្ញុំ... ពេលដែលឃើញខ្ញុំ នាងឈប់ទ្រឹងសម្លឹងមក ដោយបញ្ជូនស្នាមញញឹមមកពីចម្ងាយ។ ខ្ញុំដើរទៅមុខរហូតទាល់តែខ្លួនខ្ញុំនិងខ្លួនរបស់នាងនៅឆ្ងាយពីគ្នាមិនដល់មួយម៉ែត្រ។

ទូរស័ព្ទនៅមិនទាន់ដាច់នៅឡើយ... កិត្យាបង្ហើបមាត់សួរតិចៗ៖

- តែយ៉ាងម៉េច?

- តែបងមិនមកមិនបាន ព្រោះ... ព្រោះបេះដូងបងនៅទីនេះ...

ខ្ញុំឃើញស្នាមញញឹមប្រកបដោយក្តីសុខលេចឡើងលើវង្ងង់មុខរបស់កិត្យា... ភ្នែកទាំងគូដែលខ្ញុំស្រឡាញ់នាពេលនេះចាំងរស្មីព្រិចៗ ហើយបន្តិចក្រោយមក ទឹកថ្លាៗក៏ប្រាលចេញពីរចុងភ្នែករបស់នាង ដែលបញ្ជាក់ឲ្យខ្ញុំដឹងច្បាស់ថា នាងមានក្តីសុខប៉ុណ្ណា...

***

# សមាគមសេរីភាព
# LIBERTY ASSOCIATION

សមាគម សេរីភាព (Liberty Association) បង្កើតឡើងចាប់ពីឆ្នាំ 2009 ក្នុងគោលបំណង ជួយលើកកំពស់វិស័យអក្សរសាស្រ្ត និងអក្សរសិល្ប៍ នៅក្នុងប្រទេសកម្ពុជា។

ក្នុងពេលបច្ចុប្បន្ន សមាគមបង្កើត គេហទំព័រសៀវភៅជាភាសាខ្មែរ សំរាប់អ្នកអានជនជាតិខ្មែរ ដែលនៅទូទាំងពិភពលោក។

លឹម សន្តិភាព